# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ហ្សុង ជាន ជីន ហ្សៀន ជីង ជី តេ ឈូ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ហ្ស៊ុង ជាន ជីន បៀន ជីង ជី តេ ឈូ** (ZHONG JIAN JIN BIAN JING JI TE QU SEZ) ដែលមានទីតាំងស្ថិតនៅភូមិសូរង្ស ភូមិបឹងកក់ និងភូមិឡពាង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ហ្ស៊ុង ជាន ជីន បៀន ជីង ជី តេ ឈូ** មានទំហំ ៤៧០,២៨ ហិកតា (បួនរយចិតសិបហិកតា និងម្ភៃប្រាំបីអា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ហ្ស៊ុង ជាន ជីន បៀន ជីង ជី តេ ឈូ** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ហ្ស៊ុង ជាន ជីន បៀន ជីង ជី តេ ឈូ** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងក្រុមហ៊ុន ហ្សុង ជាន ជីន បៀន ជីង ជី តេ ឈូ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា សោភា**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ